**AIA (Cambodia) Life Insurance Plc**
12th Floor, Exchange Square,
Street 106 – 61, Sangkat Wat Phnom,
Khan Daun Penh,
Phnom Penh, Kingdom of Cambodia
AIA.COM.KH

Media Release

# ភាពជាដៃគូអាជីវកម្មប៊េងកាស្សួរេនរវាង អេ អាយ អេ ខេមបូឌា និងធនាគារ ព្រីនស៍ នឹងផ្តល់ភាពងាយស្រួលដល់អតិថិជន និងបទពិសោធផ្នែកហិរញ្ញវត្ថុកាន់តែប្រសើរឡើង

**ភ្នំពេញ ថ្ងៃទី 12 ខែមករា ឆ្នាំ 2022៖** ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនស្សួរេន ម.ក (អេ អាយ អាយ ខេមបូឌា) និងធនាគារ ព្រីនស៍ ម.ក បានប្រកាសចាប់ផ្តើមភាពជាដៃគូអាជីវកម្មប៊េងកាស្សួរេន ដើម្បីផ្តល់ជូនអតិថិជននូវសេវាកម្មហិរញ្ញវត្ថុ ដ៏ងាយស្រួល និងល្អបំផុតនៅនឹងមួយកន្លែង រួមមានទាំងដំណោះស្រាយផ្នែកធនាគារ និងធានារ៉ាប់រងអាយុជីវិត។

ពិធីចុះហត្ថលេខានេះ ត្រូវបានអញ្ជើញចូលរួមក្រោមវត្តមានដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ច័ន្ទភីរូ** អគ្គនាយកនៃនិយ័តករធានារ៉ាប់រងកម្ពុជា **ឯកឧត្តម រត្ន័ សុវណ្ណនរៈ** អគ្គនាយកត្រួតពិនិត្យនៃធនាគារជាតិនៃកម្ពុជា **លោក ហ៊ុយ វ៉ាថារ៉ូ** ប្រធានសមាគមធានារ៉ាប់រងកម្ពុជា **លោក ប៊ុន យីន** អនុប្រធានសមាគមធនាគារនៅកម្ពុជា និងថ្នាក់ដឹកនាំជាន់ខ្ពស់មកពី អេ អាយ អាយ គ្រុប អេ អាយ  អេ ខេមបូឌា និងធនាគារ ព្រីនស៍។

កិច្ចព្រមព្រៀងភាពជាដៃគូរយៈពេលប្រាំឆ្នាំរវាងស្ថាប័នឈានមុខគេទាំងពីរនេះ នឹងធ្វើឱ្យសេវាធានារ៉ាប់រងកាន់តែមានភាពងាយស្រួល ទូលំទូលាយ និងការរៀបចំផែនការហិរញ្ញវត្ថុ ដែលផ្តោតលើសុវត្ថិភាពហិរញ្ញវត្ថុរយៈពេលវែង។ គម្រោងផែនការធានារ៉ាប់រងអាយុជីវិត និងសុខភាពដ៏ពេញលេញរបស់ អេ អាយ អេ ខេមបូឌា នឹងមានវត្តមានគ្រប់ទីកន្លែងទៅតាមបណ្តាសាខាទាំង 32 របស់ធនាគារ ព្រីនស៍ ក្នុងខេត្តចំនួន 22 ទូទាំងប្រទេស។

កិច្ចសហការនេះគឺស្របតាមយុទ្ធសាស្ត្រប៊េងកាស្សួរេនរបស់ អេ អាយ អេ ខេមបូឌា ក្នុងការចាប់ដៃគូជាមួយស្ថាប័នហិរញ្ញវត្ថុឈានមុខ ដើម្បីបង្កើនការយល់ដឹង និងការជ្រៀតចូលទីផ្សារនៃសេវាកម្មធានារ៉ាប់រងអាយុជីវិត។ នៅពេលដែលប្រជាជនកម្ពុជាកាន់តែយល់ដឹងច្បាស់អំពីសុខភាព និងសុខុមាលភាព ភាពជាដៃគូនេះអនុញ្ញាតឱ្យ អេ អាយ អេ ខេមបូឌា ផ្តល់ជូនការប្រឹក្សាពីអ្នកជំនាញ តាមរយៈផ្តល់ការណែនាំនូវដំណោះស្រាយប្រកបដោយគុណភាព និងផែនការផ្នែកហិរញ្ញវត្ថុល្អៗដល់ អតិថិជនរបស់ ធនាគារ ព្រីនស៍ នៅពេលដែលពួកគាត់ទៅទទួលយកសេវាធនាគារ។

**ឯកឧត្តម ប៊ូ ច័ន្ទភីរូ** អគ្គនាយកនៃនិយតករធានារ៉ាប់រងកម្ពុជាបានមានប្រសាសន៍ថា “ខ្ញុំសូមថ្លែងអំណរគុណចំពោះ ក្រុមហ៊ុន អេ អាយ អេ ខេមបូឌា និងធនាគារ ព្រីនស៍ ដែលបានខិតខំប្រឹងប្រែងរួមចំណែកអភិវឌ្ឍវិស័យធានារ៉ាប់រងនៅកម្ពុជា និងសូមលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ និងបុគ្គលិករបស់គ្រឹះស្ថានទាំងពីរដែល

**AIA (Cambodia) Life Insurance Plc**
12th Floor, Exchange Square,
Street 106 – 61, Sangkat Wat Phnom,
Khan Daun Penh,
Phnom Penh, Kingdom of Cambodia
AIA.COM.KH

# Media Release

មានវត្តមាននៅទីនេះ ឲ្យចូលរួមយ៉ាងសកម្ម ក្នុងការជំរុញការអភិវឌ្ឍវិស័យធានារ៉ាប់រងនៅកម្ពុជា ឲ្យកាន់តែទូលំទូលាយ បន្ថែមទៀតប្រកបដោយចីរភាព»។

ក្នុងពិធីនោះ **ឯកឧត្តម រត្ន័ សុវណ្ណនរៈ** អគ្គនាយកនៃអគ្គនាយកដ្ឋានត្រួតពិនិត្យនៃធនាគារជាតិកម្ពុជាបានមានប្រសាសន៍ថា "ក្នុងន័យនេះ ភាពជាដៃគូរវាងធនាគារ ព្រីនស៍ និងក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត អេ អាយ អេ ខេមបូឌា លើទម្រង់អាជីវកម្មប៊េងកាសួរេនតាមរយៈការណែនាំអតិថិជន គឺជាចំណែកមួយក្នុងការចូលរួមអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ តាមរយៈការបង្កើនលទ្ធភាពឱ្យសាធារណជនទទួលបានសេវាហិរញ្ញវត្ថុប្រកបដោយបរិយាបន្ន និងការពង្រឹងកិច្ចការពារអតិថិជនព្រមទាំងការបង្កើនចំណេះដឹងផ្នែកហិរញ្ញវត្ថុផងដែរ។"

លោក Andrew Loh អគ្គនាយកប្រតិបត្តិនៃក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត អេ អាយ អេ ខេមបូឌា បានមានប្រសាសន៍ថា៖ "ភាពជាដៃគូរបស់យើងផ្តល់នូវបទពិសោធដ៏ងាយស្រួល និងអតិថិជនជាអាទិភាពចម្បងដល់អតិថិជនរបស់ ធនាគារ ព្រីនស៍ ដែលស្របតាមគោលបំណង របស់យើងក្នុងការ ជួយប្រជាជនកម្ពុជាឱ្យរស់នៅប្រកបដោយសុខភាព និងជីវិតកាន់តែប្រសើរ។ នេះក៏ជាការបើកស្វាគមន៍ សម្រាប់យើងខ្ញុំក្នុងការផ្តល់នូវតម្លៃកាន់តែ ខ្លាំងតាមរយៈការចែករំលែកពីរបៀបដែលសេវាធានារ៉ាប់រង អាយុជីវិតផ្តល់ផលវិជ្ជមានដល់សុខភាព និងសុវត្ថិភាពហិរញ្ញវត្ថុក្នុងពេលបច្ចុប្បន្នក៏ដូចជានាពេលអនាគត។

លោកក៏បានបន្ថែមទៀតថា "តាមទស្សនៈអាជីវកម្ម អេ អាយ អេ ខេមបូឌា និងធនាគារ ព្រីនស៍ ក៏អាចពង្រីក និងផ្លាស់ប្តូរជំនាញបច្ចេកវិទ្យា និងទីផ្សារ ដើម្បីពង្រីកបណ្តាញចែកចាយ និងជួយដល់អតិថិជន ស្របតាមការសន្យារបស់យើងក្នុងការពន្លឿនកំណើនវិស័យធានារ៉ាប់រង និងប៊េងកាសួរេន"

**លោក ហ៊ន់ សុរចនា** ប្រធាននាយកប្រតិបត្តិ និងជានាយកគ្រប់គ្រង ធនាគារ ព្រីនស៍ មានប្រសាសន៍ថា "ក្នុងនាមជាធនាគារកម្ពុជាមួយដែលទទួលបានពានរង្វាន់ និងការទទួលស្គាល់ជាច្រើនពីស្ថាប័នអន្តរជាតិ អតិថិជនរបស់យើងបានពឹងផ្អែកក្នុងការចែកចាយផលិតផល និងសេវាកម្មលំដាប់ពិភពលោក ដែលផ្តល់ជូនបន្ថែមសម្រាប់ពួកគាត់។
តាមរយៈការចាប់ដៃគូជាមួយក្រុមហ៊ុនធានារ៉ាប់រងឈានមុខគេមួយរបស់ពិភពលោក យើងនឹងអាចផ្តល់ជូនអតិថិជនរបស់យើងនូវលទ្ធភាពទទួលបានផលិតផលធានារ៉ាប់រងអាយុជីវិតដែលមានគុណភាពខ្ពស់ ស្របតាមតម្រូវការ និងសេវាកម្មដែលផ្តល់ការការពារស្របតាមតម្រូវការរបស់ពួកគេ។

សម្រាប់ព័ត៌មានបន្ថែមអំពីការផ្តល់ជូនរបស់ អេ អាយ អេ ខេមបូឌា តាមរយៈធនាគារ ព្រីនស៍ និងរបៀបដែលជួយអ្នកក្នុងការរៀបចំផែនការ និងសន្សំសម្រាប់ពេលអនាគត សូមទៅកាន់សាខាណា មួយរបស់

**AIA (Cambodia) Life Insurance Plc**
12th Floor, Exchange Square,
Street 106 – 61, Sangkat Wat Phnom,
Khan Daun Penh,
Phnom Penh, Kingdom of Cambodia
AIA.COM.KH

# Media Release

ធនាគារ ព្រីនស៍ ឬ សូមទាក់ទងមកកាន់សេវាអតិថិជន អេ អាយ អេ តាមរយៈលេខ 086 999 242 ឬចូលទៅកាន់គេហទំព័រ aia.com.kh ។

សម្រាប់ព័ត៌មានបន្ថែមអំពីផលិតផល និងសេវាកម្មរបស់ធនាគារ ព្រីនស៍ សូមទាក់ទង 1800 20 8888 ចូលទៅកាន់គេហទំព័រ www.princebank.com.kh ឬចូលទៅកាន់សាខារបស់យើងដែលមានទីតាំងនៅទូទាំងប្រទេស។

***អំពី អេ អាយ អេ***

*អេ អាយ អេ គ្រុប លីមីតធីត និង សាខា (តទៅហៅថា អេ អាយ អេ "AIA" ឬ គ្រុប "Group") មានក្រុមហ៊ុនធានារ៉ាប់រងជីវិតនៅទូទាំងតំបន់អាស៊ីដែលស្ថិតក្នុងបញ្ជីឈ្មោះសាធារណៈឯករាជ្យធំជាងគេ ។ ក្រុមហ៊ុនមានវត្តមាននៅលើទីផ្សារចំនួន ១៨ ប្រទេសនៅអាស៊ីប៉ាស៊ីហ្វិក - សាខាគ្រប់គ្រងទាំងស្រុង និង ក្រុមហ៊ុនបុត្រសម្ព័ន្ធនៅទីក្រុងហុងកុង SAR ប្រទេសថៃ សឹង្ហបូរី ម៉ាឡេស៊ី ចិនដីគោក កូរ៉េខាងត្បូង ហ្វីលីពីន អូស្ត្រាលី ឥណ្ឌូនេស៊ី (ចិន) តៃវ៉ាន់ វៀតណាម ញ៉ូហ្ស៊ីលែន ម៉ាកាវ SAR ប្រ៊ុយណេ កម្ពុជា មីយ៉ាន់ម៉ា ក្រុមហ៊ុនបុត្រសម្ព័ន្ធដែល ៩៩ ភាគរយនៅប្រទេសស្រីលង្កា និង ក្រុមហ៊ុនបណ្តាក់ទុនរួម ៤៩ ភាគរយនៅប្រទេសឥណ្ឌា។*

*ក្នុងពេលបច្ចុប្បន្ន អាជីវកម្មរបស់ក្រុមហ៊ុន គឺដូចគ្នានិង អេអាយអេ ដែលត្រូវបានបង្កើតឡើងលើកដំបូងនៅទីក្រុងសៀងហៃ កាលពីមួយសតវត្សកន្លងទៅក្នុងឆ្នាំ ១៩១៩ ។ ជាក្រុមហ៊ុនឈានមុខគេមួយនៅលើទីផ្សារ ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក (អតីត-ជប៉ុន) ដោយផ្តោតទៅលើបុព្វលាភធានារ៉ាប់រងជីវិត និងមានតួនាទីនាំមុខគេនៅគ្រប់ទីផ្សារភាគច្រើនរបស់ខ្លួន ។ ក្រុមហ៊ុនមានទ្រព្យសម្បត្តិសរុបចំនួន ៣២៦ ពាន់លានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។*

*អេ អាយ អេ ឆ្លើយតបតាមតម្រូវការនៃប្រាក់សន្សំ និង ការការពាររយៈពេលវែងរបស់ ពលរដ្ឋទូទៅតាមរយៈការផ្តល់នូវផលិតផលដ៏សម្បូរបែប និង សេវាកម្មជាច្រើនរួមមាន ការធានារ៉ាប់រងជីវិត គ្រោះថ្នាក់ ការធានារ៉ាប់រងសុខភាព និង ផែនការសន្សំប្រាក់ ។ ក្រុមហ៊ុនគ្រុប ក៏ផ្តល់ផងដែរនូវប្រាក់អត្ថប្រយោជន៍សម្រាប់បុគ្គលិក ផ្តល់ឥណទានអាយុជីវិត និង សេវាកម្មប្រាក់សោធនិវត្តន៍ ។ តាមរយៈបណ្តាញភ្នាក់ងារ ដៃគូ និង បុគ្គលិកដ៏ទូលំទូលាយនៅទូទាំងតំបន់អាស៊ីប៉ាស៊ីហ្វិក អេអាយអេ បានផ្តល់ដល់ម្ចាស់ប័ណ្ណធានានូវ ប័ណ្ណធានារ៉ាប់រងរូបវ័ន្តបុគ្គលច្រើនជាង ៣៨ លាននាក់ និង សមាជិកដែលបានចូលរួម ផែនការធានារ៉ាប់រងជាក្រុមជាង ១៦ លាននាក់។*

*អេ អាយ អេ គ្រុបលីមីតធិត (AIA Group Limited) ត្រូវបានដាក់បញ្ចូលក្នុង តារាងនៃក្រុមប្រឹក្សាភិបាលចម្បងនៃ គណកម្មាធិការផ្សារមូលបត្រទីក្រុងហុងកុង (Main Board of The Stock Exchange of Hong Kong Limited) ដែលស្ថិតក្រោមច្បាប់ផ្សារមូលបត្រ "១២៩៩" ស្របតាមច្បាប់ស្តីពី ការទទួលប្រាក់តម្កល់*

**AIA (Cambodia) Life Insurance Plc**
12th Floor, Exchange Square,
Street 106 – 61, Sangkat Wat Phnom,
Khan Daun Penh,
Phnom Penh, Kingdom of Cambodia
AIA.COM.KH

# Media Release

*នៃសហរដ្ឋអាមេរិក (កម្រិត ១) A (American Depositary Receipts (Level 1) ដែលធ្វើពាណិជ្ជកម្មលើទីផ្សារស្របច្បាប់ (រូបសញ្ញា: "AAGIY" )។*

***<u>អំពីធនាគារ ព្រីនស៍ ម.ក</u>***

*ធនាគារ ព្រីនស៍ ម.ក បានចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួន ក្នុងឆ្នាំ2015 ក្នុងនាមជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឯកជនមួយ ដែលមានឈ្មោះចាស់ថា "គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ព្រីនស៍ ហ្វាយនែន ភីអិលស៊ី" ហើយត្រូវបានប្រែក្លាយទៅជាធនាគារពាណិជ្ជ ដែលមានអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការធនាគារលេខធ46 ពីធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី18 ខែកក្កដា ឆ្នាំ2018។ ដោយមានមូលដ្ឋានដើមទុនដ៏រឹងមាំ ជាមួយនឹងការប្រើប្រាស់បច្ចេកវិទ្យាទំនើប ប្រកបដោយជំនាញច្បាស់លាស់ និងការយល់ដឹងយ៉ាងទូលំទូលាយអំពីទីផ្សារក្នុងស្រុក ធនាគារ ព្រីនស៍ ម.ក មានភាពជឿជាក់ក្នុងការក្លាយជាគ្រឹះស្ថានឈានមុខក្នុងវិស័យធនាគារ ដោយផ្តល់ដំណោះស្រាយហិរញ្ញវត្ថុច្រើនជម្រើស និងសម្បូរបែបដល់អតិថិជនរបស់យើង តាមរយៈសេវាកម្ម និងផលិតផលជាច្រើនប្រភេទ ដែលប្រកបដោយភាពងាយស្រួល និងបទពិសោធន៍ដ៏ល្អឥតខ្ចោះ ជូនអតិថិជនរបស់យើង។ យើងមានចំណាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការរួមចំណែកដល់ការអភិវឌ្ឍន៍ សហគ្រាសធុនតូច និងមធ្យម ដែលជាផ្នែកដ៏សំខាន់មួយនៃអតិថិជនគោលដៅរបស់យើង។ បច្ចុប្បន្ននេះយើងមានសាខាចំនួន 32 និងទីតាំងអេធីអឹមចំនួន 74 នៅទូទាំងប្រទេស។*

---

***ទំនាក់ទំនងសារព័ត៌មាន***
***ម៉េង ដាណែត***
*ប្រធានផ្នែកទីផ្សារជាន់ខ្ពស់*
*អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក*
*<u>Daneth-d.Meng@aia.com</u>*